ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

## សារជូនពរ

ផ្ញើជូន

**នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ**
**ក្នុងឱកាសពិធីចូលឆ្នាំថ្មីឆ្នាំសកល២០២២**

**មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហាន គ្រប់ស្ថាប័ន កងឯកភាព នៃកងយោធពលខេមរភូមិន្ទទាំងអស់ ជាទីស្នេហា !**

ក្នុងឱកាសដ៏វិសេសវិសាល ប្រកបដោយសេចក្តីសោមនស្សរីករាយ នៃទិវាចូលឆ្នាំថ្មីឆ្នាំសកល២០២២ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្ញុំផ្ទាល់ សូមផ្ញើជូននូវការសាកសួរសុខទុក្ខ ដោយក្តីនឹករលឹកនិងជាទីស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅបំផុត ចំពោះមេបញ្ជាការ មេបញ្ជាការរងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ក្នុងកងយោធពលខេមរភូមិន្ទ ដែលកំពុងបំពេញភារកិច្ចនៅតាមស្ថាប័ន កងឯកភាពនានា ក៏ដូចជាសិក្ខាកាមកំពុងសិក្សាជំនាញផ្សេងៗទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ព្រមទាំងកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។សូមជូននូវសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខ សូមទទួលបាននូវសេចក្តីសុខចៀសផុតពីជំងឺរាលដាលកូវីដ-១៩ ដ៏កាចសាហាវដែលបាននិងកំពុងគំរាមកំហែងនៅទូទាំងពិភពលោកនាពេលបច្ចុប្បន្ន។

នាឱកាសដ៏ឧត្តុង្គឧត្តមនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរយ៉ាងស្មោះ ចំពោះជោគជ័យដ៏ត្រចះត្រចង់ដែលកងយោធពលខេមរភូមិន្ទយើងសម្រេចបាននូវសមិទ្ធផលដ៏ធំធេងក្នុងឆ្នាំកន្លងមក កើតចេញពីការលះបង់និងការខិតខំពុះពារជម្នះគ្រប់ឧបសគ្គនិងការលំបាក ធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារជាតិមាតុភូមិ ការពារសន្តិសុខជាតិ ថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ និងភាពសុខក្សេមក្សាន្តរបស់ប្រជាជន ហើយកងយោធពលខេមរភូមិន្ទយើងក៏បានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការបង្ការទប់ស្កាត់ ការពារ និងសង្គ្រោះប្រជាពលរដ្ឋជនរួមជាតិទាំងអស់ ឱ្យរួចផុតពីគ្រោះនៃការឆ្លងរាលដាលពីជំងឺកូវីដ-១៩ដ៏កាចសាហាវនេះផងដែរ។

ទន្ទឹមនេះកងយោធពលខេមរភូមិន្ទយើង បានចូលរួមអនុវត្តប្រកបដោយជោគជ័យនូវភារកិច្ចអន្តរជាតិលើវិស័យមនុស្សធម៌ បំពេញបេសកកម្មជាកងកម្លាំងរក្សាសន្តិភាព ក្រោមឆត្ររបស់អង្គការសហប្រជាជាតិ នៅបណ្តាតំបន់មួយចំនួន ដើម្បីបុព្វហេតុសន្តិភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិល្អ ដែលជាក្តីមោទនភាព និងជាកិត្តិយសដ៏ខ្ពង់ខ្ពស់របស់កងយោធពលខេមរភូមិន្ទ ក៏ដូចជាប្រជាជាតិកម្ពុជាយើងទាំងមូល។

សរុបមកវិញ រាល់សមិទ្ធផលដ៏ធំធេងដែលសម្រេចបានកន្លងមកនេះ គឺអាស្រ័យដោយការខិតខំប្រឹងប្រែងតស៊ូលះបង់ពុំខ្លាចនឿយហត់ និងការធ្វើពលិកម្មគ្រប់បែបយ៉ាង គួបផ្សំជាមួយនឹងស្មារតីទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំគ្រប់ស្ថាប័ន កងឯកភាព ក្នុងការចាត់តាំងអនុវត្តការងារសម្រេចបានលទ្ធផលល្អប្រសើរ។

**មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ជាទីស្នេហា !**

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្នុងនាមខ្ញុំផ្ទាល់ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតារក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្ទសាធុការពរជ័យ សិរីមង្គល

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២៧៨: generalsec@mod.gov.kh

ជូនចំពោះនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ អាយុយឺនយូរ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ចជូនជាតិមាតុភូមិនិងប្រជាពលរដ្ឋនៃយើង។

សូមផ្ញើជូននូវការសួរសុខទុក្ខដល់យោធិន ជំងឺ របួស ពិការ ដែលកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យនានា សូមឱ្យបានឆាប់ជាសះស្បើយពីជំងឺ មានសុខភាពល្អបរិបូរណ៍ កម្លាំងរឹងមាំ និងប្រកបដោយសេចក្តីសុខ។

សូមជូនពរដល់អតីតយុទ្ធជនព្រមទាំងក្រុមគ្រួសារ ដែលកំពុងរស់នៅក្នុងសង្គមស៊ីវិល សូមមានជីវភាពរស់នៅធូរធានិងប្រកបដោយសុភមង្គលរុងរឿង។

សូមផ្ញើជូន មេបញ្ជាការ មេបញ្ជាការរង គ្រប់ស្ថាប័ន កងឯកភាព នាយទាហាន នាយទាហានរង និងពលទាហានក្នុងកងយោធពលខេមរភូមិន្ទ ទាំងសិក្ខាកាមដែលកំពុងបំពេញការសិក្សាជំនាញផ្សេងៗនៅតាមបណ្តាប្រទេសជាមិត្ត រួមទាំងកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាពក្រោមកិច្ចសហប្រតិបត្តិការអន្តរជាតិ របស់អង្គការសហប្រជាជាតិ ព្រមទាំងក្រុមគ្រួសារ ត្រូវអនុវត្តឱ្យបានតាមការណែនាំរបស់រាជរដ្ឋាភិបាល និងប្រកាន់ខ្ជាប់នូវវិធានការការពារនានារបស់ក្រសួងសុខាភិបាល ៣កុំ ៣ការពារ គឺត្រូវពាក់ម៉ាស់ លាងដៃជាមួយសាប៊ូ អាកុល ឬជែលរក្សាគម្លាតសុវត្ថិភាព ដើម្បីបង្ការទប់ស្កាត់ និងការពារឱ្យរួចផុតពីគ្រោះនៃការឆ្លងរាលដាលពីជំងឺកូវីដ-១៩ ដ៏កាចសាហាវនេះ និងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** ជានិច្ចនិរន្តរ៍តរៀងទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**